# វិសុទ្ធិមគ្គ

## ( សម្រាប់សូត្រ )

ផ្សាយចេញពីវត្តនិគ្រោធវ័ន "គល់ទទឹង"
ភូមិកោះក្របី សង្កាត់ព្រែកថ្មី ខណ្ឌមានជ័យ រាជធានីភ្នំពេញ

ប្រមូលរៀបរៀងដោយ
ខ្ញុំព្រះករុណាអាត្មាភាព
សាមណេរ មហោរថ យ៉ុន តាក

# វិសុទ្ធិមគ្គ

(សម្រាប់សូត្រ)

រៀបរៀងដោយ

**សាមណេរ មនោរថ យ៉ូន តារា**

ការផ្សាយចេញរបស់វត្តនិគ្រោធវ័ន(គល់ទទឹង)

ព.ស.២៤៤៨

ឈ្មោះសៀវភៅ ៖ វិសុទ្ធិមគ្គ(សម្រាប់សូត្រ)

ប្រមូលរៀបរៀងដោយ ៖ **សាមណេរ មនោរថ យ៉ូន តារា**

ផ្ទៀងផ្ទាត់ដោយ ៖

ព្រះធម្មាចារ្យ **ម៉ន សាមី**

ព្រះធម្មាចារ្យ **អ៊ុន ពិសី**

ព្រះធម្មាចារ្យ **ចាន់ គង់**

វិនយកោវិទ **ខណ្ណ គមសាន**

វិនយកោវិទ **ហ៊ាន សុខហៃ**

វិនយកោវិទ **យ៉ូន តារា**

កាលបរិច្ឆេទ ៖ ព.ស. ២៥៥៨ គ.ស.២០១៤

ស្ថានទីធ្វើ ៖ វត្តនិគ្រោធវ័ន "គល់ទទឹង" ភូមិកោះក្របី
សង្កាត់ព្រែកថ្មី ខ័ណ្ឌមានជ័យ
រាជធានីភ្នំពេញ

បោះពុម្ពលើកទី១ ៖ ថ្ងៃ៣កើត ខែស្រាពណ៍ ព.ស.២៥៥៨

រក្សាសិទ្ធិដោយ ៖ វត្តនិគ្រោធវ័ន "គល់ទទឹង"

# កថាប្រមុខ

ខ្ញុំព្រះករុណាអាត្មាភាពបានប្រមូលរៀបរៀងសៀវភៅ “វិសុទ្ធិមគ្គ (សម្រាប់សូត្រ)” នេះឡើង គឺ ដើម្បីឲ្យអ្នកសិក្សាវិសុទ្ធិមគ្គក្នុងសីលនិទ្ទេសងាយយល់ ព្រោះខ្ញុំលើកមកនេះ គឺ យកចំណុចដែលត្រូវចងចាំ ។ ហើយខ្ញុំបានប្រមូលរៀបរៀងទៅតាមលំដាប់នៃមាតិកានីមួយៗ ក្នុងការស្វាធ្យាយយ៉ាងផ្ចិតផ្ចង់បំផុត មិនឲ្យឃ្លៀងឃ្លាតពីច្បាប់ដើម និងការសូត្រនៃព្រះថេរៈទាំងឡាយដែលលោកបានសិក្សាពីមុនៗមក ហើយខ្ញុំក៏សូមអរព្រះគុណខ្លាំងណាស់ចំពោះលោកម្ចាស់គ្រូ **វិនយធរោ តុន ប៊ុនសាយ** ដែលបានជួយប្រែភាសាបាលីនៅចំណុចខ្លះ ម្យ៉ាងទៀតដើម្បីជាប្រយោជន៍ដល់កុលបុត្តអ្នកមានសទ្ធាជ្រះថ្លាក្នុងការសិក្សាគម្ពីរព្រះវិសុទ្ធិមគ្គនេះ ។

ខ្ញុំសូមឧទ្ទិសសៀវភៅនេះ ដល់សមណសិស្សគ្រប់ព្រះអង្គ និងពុទ្ធសាសនិកជនទូទៅ សូមយកទៅសិក្សាឲ្យបានឆាប់ចេះឆាប់យល់ ឆ្លៀវឆ្លាតក្នុងព្រះបរិយត្តិធម៌ ហើយយកព្រះធម៌នោះទៅផ្សព្វផ្សាយដល់ពុទ្ធបរិស័ទទាំងឡាយ ដើម្បីលើកស្ទួយព្រះពុទ្ធសាសនា ឲ្យបានរីកចម្រើនឡើង រៀងតទៅ ។

សូមសាធុជនទាំងឡាយ ដែលមានភក្តីភាពចំពោះព្រះរតនត្រ័យនោះ សូមត្រេកអរអនុមោទនា នូវបុញ្ញកុសលរបស់ខ្ញុំ ដែលខិតខំព្យាយាម

បំពេញក្នុងព្រះពុទ្ធសាសនានេះ សូមពួកញាតិ និងសព្វសត្តនិករ មួយអន្លើដោយពុទ្ធបរិស័ទទាំងឡាយ ចូរបានសេចក្ដីសុខ ឲ្យមានសេចក្ដីក្សេម ចូរជាអ្នកសោយរសនៃព្រះសទ្ធម្មរបស់ព្រះមានព្រះភាគចុះ ។

ម្យ៉ាងទៀត ដោយអំណាចមហាកុសលនេះ សូមបានជាឧបនិស្ស័យនៃការត្រាស់ដឹងនូវធម៌ ដល់ព្រមដោយបដិសម្ភិទាក្នុងសាសនារបស់ព្រះមានព្រះភាគ ក្នុងកាលជាអនាគតទៅហោង...

សូមអនុមោទនា!!!

**វត្តនិគ្រោធវ័ន(គល់ទទឹង)**

ថ្ងៃសុក្រ ១រោច ខែជេស្ឋ ឆ្នាំមមី ឆស័ក ព.ស.២៥៥៨

**សាមណេរ មនោរថ យ៉ុន តារា**

# វិសុទ្ធិមគ្គ

( សម្រាប់សូត្រ )

ប្រមូលរៀបរៀងដោយ

ខ្ញុំព្រះករុណា អាត្មាភាព

សាមណេរ មនោរថ យ៉ុន តារា

## **វិសុទ្ធិមគ្គ ព្រះគាថា**

**សីលេ បតិដ្ឋាយ នរោ សប្បញ្ញោ ចិត្តំ បញ្ញញ្ច ភាវយំ អាតាបី និបកោ ភិក្ខុ សោ ឥមំ វិជដយេ ជដំ ។**

*នរជនណាប្រកបដោយបញ្ញា មានព្យាយាមជាគ្រឿងដុតកំដៅកិលេស មានប្រាជ្ញាចាស់ក្លា ឃើញភ័យក្នុងវដ្តៈ កាលតាំងនៅស៊ប់ក្នុងសីល ហើយអប់រំចិត្តចម្រើនបញ្ញា នរជននោះអាចកាប់ឆ្ការនូវព្រៃស្តុកគឺតណ្ហានេះបាន ។*

## **បរិយាយគាថា**

**១. សីលំ បរិបូរយមានោយេវ ចេត្ថ សីលេ ឋិតោតិ វុច្ចតិ តស្មា សីលបរិបូរណេន សីលេ បតិដ្ឋហិត្វាតិ អយមេត្ថ អត្ថោ ។** *នរជនកាលញុំាងសីលឲ្យបរិបូណ៌ពេញលេញ ព្រះមានព្រះភាគត្រាស់ថា តាំងនៅក្នុងសីល ព្រោះហេតុនោះលោកអធិប្បាយថា នរជនណាតាំងនៅស៊ប់ហើយក្នុងសីល*

*ដោយកិរិយាបំពេញសីលឲ្យបរិបូណ៌ ក្នុងប្រយោគថា* ***“សីលេ បតិដ្ឋាយ”*** *នេះ ។*

**២. នរោ សត្តោ** *បទថា* ***“នរោ”*** *បានដល់សត្វ ។*

**៣. សប្បញ្ញោតិ កម្មជតិហេតុកបដិសន្ធិប្បញ្ញាយ បញ្ញវា ។** *បទថា* ***“សប្បញ្ញោ”*** *បានដល់ នរជនប្រកបដោយបញ្ញា អំពីកំណើត ជាតិហេតុកបដិសន្ធិ ។*

**៤. ចិត្តំ បញ្ញញ្ច ភាវយន្តិ សមាធិញ្ចេវ វិបស្សនញ្ច ភាវយមានោ ។** *ប្រយោគថា* ***“ចិត្តំ បញ្ញញ្ច ភាវយំ”*** *បានដល់ នរជនកាលចម្រើននូវសមាធិនិងវិបស្សនា ។*

**៥. អាតាបីតិ វីរិយវា ។** *បទថា* ***“អាតាបី”*** *បានដល់នរជនមានសេចក្ដីព្យាយាម(ជាគ្រឿងដុតកំលោចកិលេស) ។*

**៦. និបកោតិ នេបក្កំ វុច្ចតិ បញ្ញា តាយ សមន្នាគតោតិ អត្ថោ ។** *បញ្ញាចាស់ក្លាព្រះមានព្រះភាគត្រាស់ថា* **“និបកោ”** *អធិប្បាយថា នរជនប្រកបព្រមដោយនេបក្កៈបញ្ញានោះ ។*

**ឯត្តាវតា ហិ**

*សេចក្ដីប៉ុណ្ណេះព្រះមានព្រះភាគប្រកាសគុណ ៥យ៉ាងគឺ៖*

**១. តិស្សោ សិក្ខា** *សិក្ខាបី ។*

**២. តិវិធកល្យាណំ សាសនំ** *លម្អសាសនាបី ។*

**៣. តេវិជ្ជតាទីនំ ឧបនិស្សយោ** *ឧប្បនិស្ស័យដល់វិជ្ជាបីជាដើម ។*

**៤. អន្តទ្វយវជ្ជនមជ្ឈិមបដិបត្តិសេវនានិ** *វៀរចាកផ្លូវអមពីរ ហើយសេពនូវមជ្ឈិមាបដិបទា ។*

**៥. អបាយាទិសមតិក្កមឧបាយោ** *ឧបាយជាគ្រឿងកន្លងគតិមានអបាយជាដើម ។*

**៦. តីហាការេហិ កិលេសប្បហានំ** *កិរិយាលះបង់កិលេស ដោយអាការបីយ៉ាង ។*

**៧. វីតិក្កមាទីនំ បដិបក្ខោ** *ធម៌ជាបដិបក្ខចំពោះកិលេស(មាន វីតិក្កមកិលេស)ជាដើម ។*

**៨. សំកិលេសត្តយវិសោធនំ** *កិរិយាជម្រះកិលេសបីយ៉ាង មានទុច្ចរិតសង្កិលេសជាដើម ។*

**៩. សោតាបន្នាទិភាវស្ស ច ការណំ** *ដំណើរនៃព្រះអរិយៈ មានសោតាបន្នបុគ្គលជាដើម ។*

## សីលនិទ្ទេស

### *គាថាសម្ដែងតួនាទីរបស់សីល*

**សាសនេ កុលបុត្តានំ បតិដ្ឋា នត្ថិ យំ វិនា អានិសំសប-រិច្ឆេទំ តស្ស សីលស្ស កោ វទេ ។** *ទីពឹងរបស់កុលបុត្រទាំង-*

ឡាយក្នុងសាសនានេះ វៀរចាកសីលហើយនឹងមានមកពីណា តើបុគ្គលណាអាចកំណត់នូវអានិសង្សរបស់សីលបាន ។

## បុច្ឆាការៈ ៧យ៉ាង

១. កឹ សីលំ *អ្វីជាតួសីល?*

២. កេនដ្ឋេន សីលំ *សីលដោយអត្ថថាដូចម្ដេច?*

៣. កានស្ស លក្ខណរសបច្ចុប្បដ្ឋានបទដ្ឋានានិ *តើលក្ខណៈ កិច្ចអាការៈប្រាកដ និងហេតុជិតរបស់សីលដូចម្ដេច?*

៤. កិមានិសំសំ សីលំ *តើសីលមានអានិសង្សដូចម្ដេច?*

៥. កតិ វិធញ្ចេតំ សីលំ *តើសីលមានប្រការប៉ុន្មាន?*

៦. កោ ចស្ស សង្កិលេសោ *អ្វីជាគ្រឿងសៅហ្មងរបស់សីល?*

៧. កឹ វោទានំ *អ្វីជាគ្រឿងផូរផង់របស់សីល?*

## វិសជ្ជនាការៈ

**១. កឹ សីលន្តិ ចេតនា សីលំ ចេតសិកំ សីលំ សំវរោ សីលំ អវិតក្កមោ សីលំ ។** *ក្នុងបដិសម្ភិទាមគ្គឆ្លើយសំនួរ* ***“កឹ សីលំ”*** *ថា ចេតនាជាតួរសីល ចេតសិកជាតួរសីល សំវរៈជាតួរសីល អវិតិក្កមៈជាតួរសីល ។*

**២. កេនដ្ឋេន សីលន្តិ សីលនដ្ឋេន សីលំ** *ឆ្លើយសំនួរ* ***“កេន-ដ្ឋេន សីលំ”*** *ថា សីលដោយអត្ថថា ប្រក្រតី ។*

**ក. សមាធានំ វា កាយកម្មាទីនំ សុសីល្យវសេន អវិប្បកិណ្ណតាតិ អត្ថោ ។** *សីល(មានប្រក្រតី)រួបរួមទុក នូវកាយកម្ម វចីកម្ម អធិប្បាយថា រួបរួមទុកមិនឲ្យរាត់រាយ ដោយអំណាចភាវៈនៃសីល ជាសីលល្អ ។*

**ខ. ឧបធារណំ វា កុសលានំ ឈានំ បតិដ្ឋានវសេន អាធារភាវោតិ អត្ថោ ។** *សីល(មានប្រក្រតី) ចូលទៅទ្រទ្រង់ទុក*

*នូវធម៌ទាំងឡាយជាកុសល អធិប្បាយថា ទ្រទ្រង់ទុកយ៉ាងមាំ ដោយអំណាចសីលតាំងនៅស៊ប់ ។*

៣. ឥធានិ កានស្ស លក្ខណរសប្បច្ចុប្បដ្ឋានបទដ្ឋានានីតិ ឯត្ថ *ឆ្លើយសំនួរ* ***“កានស្ស លក្ខណរសប្បច្ចុប្បដ្ឋានានិ”*** *ថា ៖*

ក. សីលនលក្ខណំ *សីលមានប្រក្រតីជាលក្ខណៈ ។*

ខ. ទុស្សីល្យវិទ្ធំសនរសំ *សីលមានកិរិយាកម្ចាត់នូវភាព ទ្រុស្តសីល ជាកិច្ច ។*

គ. សោចេយ្យប្បច្ចុប្បដ្ឋានំ *សីលមានសេចក្ដីស្អាត(កាយ វាចាចិត្ត)ជាអាការៈប្រាកដ ។*

ឃ. ហិរិឱត្តប្បបទដ្ឋានំ *សីលមានហិរិ និងឱត្តប្បៈជា ហេតុជិត ។*

៤. កិមានិសំសំ សីលន្តិ អវិប្បដិសារាទិ អនេកគុណប្បដិ-លាភានិសំសំ *ឆ្លើយសំណួរ* ***“កិមានិសំសំ សីលំ”*** *ថា សីលមាន*

*អានិសង្សជាអនេក មានសេចក្ដីមិនក្ដៅក្រហាយជាខាងដើម មានអនុបាទាបរិនិព្វានជាខាងចុង ។*

៤. **កតិ វិធញ្ចេតំ សីលន្តិ ត្រិធំ វិសជ្ជនំ** *ឆ្លើយសំណួរ “កតិ* ***វិធញ្ចេតំ សីលំ****” ថា សីលមាន៥ប្រការ ។*

## ប្រការ ១ ឯកសីល

**សព្វមេវ តាវ ឥទំ សីលំ អត្តនោ សីលនលក្ខណេន ឯកវិធំ** *សីលទាំងអស់ ដោយលក្ខណៈរបស់ខ្លួន មានតែមួយគឺមានប្រក្រតីជាលក្ខណៈ ។*

## ប្រការ ២ ទុកៈសីល ៧ គូ

១. **ចារិត្តវារិត្តវសេន** *ដោយចារិត្តសីល និង វារិត្តសីល*

២. **អភិសមាចារិកអាទិព្រហ្មចរិយកវសេន** *ដោយអភិសមាចារិកសីល និង អាទិព្រហ្មចរិយកសីល ។*

៣. **វិរតិអវិរតិវសេន** *ដោយវិរតិសីល និង អវិរតិសីល ។*

៤. **និស្សិតានិស្សិតវសេន** ដោយនិស្សិតសីល និង អនិស្សិត-សីល ។

៥. **កាលបរិយន្តអាបាណកោដិកវសេន** ដោយកាលបរិយន្តសីល និង អាបាណកោដិកសីល ។

៦. **សបរិយន្តាបរិយន្តវសេន** ដោយសបរិយន្តសីល និង អបរិយន្តសីល ។

៧. **លោកិយលោកុត្តរវសេន** ដោយលោកិយសីល និង លោកុត្តរសីល ។

## ប្រការ ៣ តិកសីលមាន ៥តិក

១. **ហីនមជ្ឈិមបណីតវសេន** ដោយហីនសីល មជ្ឈិមសីល និង បណីតសីល ។

២. **អត្តាធិបតេយ្យលោកាធិបតេយ្យធម្មាធិបតេយ្យវសេន** *ដោយអត្តាធិបតេយ្យសីល លោកាធិបតេយ្យសីល និង ធម្មាធិ-បតេយ្យសីល ។*

៣. **បរាមដ្ឋាបរាមដ្ឋបដិប្បស្សទ្ធិវសេន** *ដោយបរាមដ្ឋសីល អបរាមដ្ឋសីល និង បដិប្បស្សទ្ធិសីល ។*

៤. **វិសុទ្ធាវិសុទ្ធវេមតិកវសេន** *ដោយវិសុទ្ធិសីល អវិសុទ្ធិសី-ល និង វេមតិកសីល ។*

៥. **សេក្ខាសេក្ខនេវសេក្ខានាសេក្ខវសេន** *ដោយសេក្ខសី-ល អសេក្ខសីល និង នេវសេក្ខានាសេក្ខសីល ។*

## ប្រការ ៤ ចតុក្កសីលមាន ៤ចតុក្ក

១. **ហានភាគិយឋិតិភាគិយវិសេសភាគិយនិព្វេធភាគិយវសេន** *ដោយហានភាគិយសីល ឋិតិភាគិយសីល វិសេសភាគិ-យសីល និងនិព្វេធភាគិយសីល ។*

**២. ភិក្ខុភិក្ខុនីអនុបសម្បន្នគហដ្ឋសីលវសេន** *ដោយភិក្ខុសី-ល ភិក្ខុនីសីល អនុបសម្បន្នសីល និងគហដ្ឋសីល ។*

**៣. បកតិអាចារធម្មតាបុព្វហេតុកសីលវសេន** *ដោយបកតិ-សីល អាចារសីល ធម្មតាសីល និងបុព្វហេតុកសីល ។*

**៤. បាតិមោក្ខសំវរឥន្ទ្រិយសំវរអាជីវបារិសុទ្ធិបច្ចយសន្និស្សិតសីលវសេន** *ដោយបាតិមោក្ខសំវរសីល ឥន្ទ្រិយសំវរសី-ល អាជីវបារិសុទ្ធិសីល និងបច្ចយសន្និស្សិតសីល ។*

**ប្រការ៥ បញ្ចកសីលមាន ២បញ្ចកៈ**

**១. បរិយន្តបារិសុទ្ធិអបរិយន្តបារិសុទ្ធិបរិបុណ្ណបារិសុទ្ធិអបរា-មដ្ឋបារិសុទ្ធិបដិប្បស្សទ្ធិបារិសុទ្ធិសីលវសេន** *ដោយបរិយន្ត-បារិសុទ្ធិសីល អបរិយន្តបារិសុទ្ធិសីល បរិបុណ្ណបារិសុទ្ធិសីល អបរាមដ្ឋបារិសុទ្ធិសីល និងបដិប្បស្សទ្ធិបារិសុទ្ធិសីល ។*

**២. បហានវេរមណីចេតនាសំវរាវីតិក្កមវសេន** *ដោយបហាន-សីល វេរមណីសីល ចេតនាសីល សំវរសីល និងអវីតិក្កមសី-ល ។*

## អធិប្បាយចតុប្បារិសុទ្ធិសីល

**យំ ភគវតា ឥធ ភិក្ខុ ចាតិមោក្ខសំវរសំវុតោ វិហរតិ អា-ចារគោចរសម្បន្នោ អណុមត្តេសុ វជ្ជេសុ ភយទស្សាវី សមា-ទាយ សិក្ខតិ សិក្ខាបទេសូតិ ឯវំ វុត្តំ សីលំ ឥទំ ចាតិមោក្ខ-សំវរសីលំ នាម ។** *សីលណាដែលព្រះមានព្រះភាគត្រាស់ថា ភិក្ខុក្នុងសាសនានេះ ជាអ្នកប្រព្រឹត្តសង្រួមក្នុងបាតិមោក្ខ បរិបូ-ណ៌ដោយអាចារនិងគោចរ មានប្រក្រតីឃើញទោសមានប្រមា-ណតិចតួចថាជាភ័យធំ សមាទានសិក្សាបដិបត្តិក្នុងសិក្ខាបទ-ទាំងឡាយ សីលនេះឈ្មោះថា បាតិមោក្ខសំវរសីល ។*

**យំ បន សោ ចក្ខុនា រូបំ ទិស្វា ន និមិត្តគ្គាហី ហោតិ នានុ-ព្យញ្ជនគ្គាហី យត្វាធិករណមេនំ ចក្ខុន្ទ្រិយំ អសំវុតំ វិហរន្តំ**

អភិជ្ឈាទោមនស្សា ចាបកា អកុសលា ធម្មា អន្វាស្សវេយ្យុំ តស្ស សំវរាយ បដិបជ្ជតិ រក្ខតិ ចក្ខុន្ទ្រិយំ ចក្ខុន្ទ្រិយេ សំវរំ អាបជ្ជតិ សោតេន សទ្ទំ សុត្វា ។បេ។ ឃានេន គន្ធំ ឃាយិត្វា ។បេ។ ជិវ្ហាយ រសំ សាយិត្វា ។បេ។ កាយេន ផោដ្ឋព្វំ ផុសិត្វា ។បេ។ មនសា ធម្មំ វិញ្ញាយ ន និមិត្តគ្គាហី ហោតិ ។បេ។ មនិន្ទ្រិយេ សំវរំ អាបជ្ជតីតិ វុត្តំ ឥទំ ឥន្ទ្រិយសំវរសីលំ នាម ។

*សីលណាដែលព្រះមានព្រះភាគត្រាស់ថា ភិក្ខុនោះ ឃើញរូបដោយចក្ខុ មិនកាន់យកនិមិត្ត និងអនុព្យញ្ជន បដិបត្តិដើម្បីបិទអកុសលទាំងឡាយដ៏លាមកមានអភិជ្ឈានិងទោមនស្សជាដើមដែលអាស្រ័យចក្ខុន្ទ្រិយមិនបានសង្រួម មិនឲ្យកើតឡើងរមែងតាមរក្សានូវឥន្ទ្រិយ៍ ដល់នូវការសង្រួមក្នុងឥន្ទ្រិយ៍ ។ ឮសម្លេងដោយត្រចៀក ។ល។ ធុមក្លិនដោយច្រមុះ ។ល។ ដឹងរសដោយអណ្ដាត ។ល។ ពាល់ត្រូវផោដ្ឋព្វដោយកាយ ។ល។ ដឹងធម្មារម្មណ៍ដោយចិត្ត មិនកាន់យកនិមិត្ត ។ល។ ដល់នូវការសង្រួមក្នុងចិត្ត សីលនេះ ឈ្មោះថា ឥន្ទ្រិយសំវរសីល ។*

**យា បន អាជីវហេតុ អាជីវការណា បញ្ញត្តានំ ឆន្នំ សិក្ខាបទានំ វីតិក្កមស្ស កុហនា លបនា នេមិត្តិកតា និប្បេសិកតា លាភេន លាភំ និជ្ជិគីសនតាតិ ឯវមាទីនញ្ចចាបធម្មានំ វសេន បវត្តា មិច្ឆាជីវា វិរតិ ឥទំ អាជីវសុទ្ធិសីលំ ។** *វិរតិរបស់ភិក្ខុមិនប្រព្រឹត្តកន្លងសិក្ខាបទទាំងឡាយ៦ ដែលព្រះមានព្រះភាគបញ្ញត្តព្រោះមានអាជីវជាហេតុ មានអាជីវជាដំណើរ និងកិរិយាវៀរចាកមិច្ឆាជីវដែលប្រព្រឹត្តទៅដោយអំណាចបាបធម៌ទាំងឡាយយ៉ាងនេះគឺ កុហនា លបនា នេមិត្តិកតា និប្បេសិកតា លាភេន លាភំ និជ្ជិគីសនតាជាដើម សីលនេះឈ្មោះថា* ***អាជីវបារិសុទ្ធិសីល*** *។*

**បដិសង្ខា យោនិសោ ចីវរំ បដិសេវតិ យាវទេវ សីតស្ស បដិឃាតាយាតិ អាទិនា នយេន វុត្តោ បដិសង្ខានបរិសុទ្ធោ ចតុបច្ចយបរិភោគោ បច្ចយសន្និស្សិតសីលំ នាម ។** *ការបរិភោគបច្ចយ៤ បរិសុទ្ធបានដោយការពិចារណា តាមន័យដែលព្រះសាស្តាត្រាស់ថា* ***“បដិសង្ខា យោនិសោ ចីវរំ បដិសេវតិ***

***យាវទេវ សីតស្ស បដិឃាតាយ***ជាដើម ឈ្មោះថា ***បច្ចយសន្និស្សិតសីល*** ។

## និទ្ទេសនៃបាបធម៌៥

**តត្ថ កតមា កុហនា?**

*បណ្តាបាបធម៌៥នោះ **កុហនា** តើដូចម្តេច?*

**លាភសក្ការសិលោកសន្និស្សិតស្ស បាបិច្ឆស្ស ឥច្ឆាបកតស្ស បច្ចយបដិសេវនសង្ខាតេន វា សាមន្តជប្បិតេន វា ឥរិយាបថស្ស វា អដ្ឋបនា ឋបនា សណ្ឋាបនា ភាកុដិកា ភាកុដិយំ កុហនា កុហាយនា កុហិតត្តំ អយំ វុច្ចតិ កុហនា ។** *ការប្រុងប្រៀបខាងដើម អាការប្រុងប្រៀង ការរៀបចំនូវឥរិយាបថ ការធ្វើមុខស្រពោន ការមានមុខស្រពោន ការធ្វើឲ្យគេស្ងើច អាការធ្វើឲ្យគេស្ងើច ភាពនៃសេចក្តីធ្វើឲ្យគេស្ងើច ដោយការសេពនូវបច្ច័យក្តី ដោយការខ្សឹបខ្សៀវក្តី របស់ភិក្ខុអ្នកអាស្រ័យលាភសក្ការៈនិងការសរសើរ មាន*

*សេចក្តីប្រាថ្នាលាមក មានសេចក្តីប្រាថ្នាគ្របសង្កត់ហើយ នេះហៅថា* ***កុហនា*** *។*

**តត្ថ កតមា លបនា**?

*បណ្តាបាបធម៌ទាំងនោះ* ***លបនា****តើដូចម្តេច?*

**លាភសក្ការសិលោកសន្និស្សិតស្ស បាបិច្ឆស្ស ឥច្ឆាបកតស្ស យា បរេសំ អាលបនា លបនា សល្លបនា ឧល្លបនា សមុល្លបនា ឧន្នហនា សមុន្នហនា ឧក្កាចនា សមុក្កាចនា អនុប្បិយភាណិតា ចាដុកម្យតា មុគ្គសូប្យតា បារិភដ្យតា អយំ វុច្ចតិ លបនា ។** *ការរាក់ទាក់រក ការនិយាយរាក់ទាក់ ចំពោះជនដទៃ ការនិយាយល្បួង ការនិយាយលើក ការនិយាយបញ្ជោរ ការនិយាយចងចិត្តត្រកូល ការបញ្ចើច ការបញ្ជោរត្រកូល ការបញ្ចើចបញ្ជោររឿយៗ ការនិយាយចាក់បណ្តោយ ការប្រព្រឹត្តបន្ទោរបន្ទន់កាយ ការប្រើវាចាដូចសម្លសណ្តែកបាយ ការបីពរទារករបស់ត្រកូលណា របស់ភិក្ខុអ្នកអាស្រ័យ*

លាភសក្ការៈនិងការសរសើរ មានសេចក្តីប្រាថ្នាលាមក មានសេចក្តីប្រាថ្នាគ្របសង្កត់ហើយ នេះហៅថា **លបនា** ។

**តត្ថ កតមា នេមិត្តិកតា**?

បណ្តាបាបធម៌៥នោះ **នេមិត្តិកតា**តើដូចម្តេច?

**លាភសក្ការសិលោកសន្និស្សិតស្ស ចាបិច្ឆស្ស ឥច្ឆាបកតស្ស យំ បរេសំ និមិត្តំ និមិត្តកម្មំ ឱភាសោ ឱភាសកម្មំ សាមន្តជប្បា បរិកថា អយំ វុច្ចតិ នេមិត្តិកតា ។** និមិត្ត ការធ្វើនូវនិមិត្ត ការនិយាយបំភ្លឺ ការធ្វើនូវសេចក្តីបញ្ចិតបញ្ចៀង ការនិយាយខ្សឹបខ្សៀវ ការនិយាយវាសវាង ចំពោះពួកជនដទៃណា របស់ភិក្ខុអ្នកអាស្រ័យលាភសក្ការៈនិងការសរសើរ មានសេចក្តីប្រាថ្នាលាមក មានសេចក្តីប្រាថ្នាគ្រប់សង្កត់ហើយ នេះហៅថា **នេមិត្តិកតា** ។

តត្ថ កតមា **និប្បេសិកតា**?

បណ្ដាបាបធម៌ទាំងនោះ **និប្បេសិកតា**តើដូចម្ដេច?

**លាភសក្ការសិលោកសន្និស្សិតស្ស បាបិច្ឆស្ស ឥច្ឆាបកតស្ស យា បរេសំ អក្កោសនា វម្ភនា គរហនា ឧក្ខេបនា សមុក្ខេបនា ខិបនា សំខិបនា បាបនា សម្បាបនា អវណ្ណហារិកា បរបិដ្ឋិមំសិកតា អយំ វុច្ចតិ និប្បេសិកតា ។** *ការជេរដោយអក្កោសវត្ថុ១០ ការបន្តុះបង្អាប់ ការតិះដៀល ការនិយាយយាត់ ការនិយាយយាត់រឿយៗ ការនិយាយចំអក ការនិយាយចំអករឿយៗ ចំពោះជនដទៃ ការញុំាងទាយកឲ្យដល់នូវទោស ការញុំាងទាយកឲ្យដល់នូវ ទោសរឿយៗ ការដឹកនាំនូវទោស ការពោលពាក្យដូចជាស៊ី សាច់ខ្នងនៃជនដទៃណា របស់ភិក្ខុអ្នកអាស្រ័យលាភសក្ការៈ និងការសរសើរ មានសេចក្ដីប្រាថ្នាលាមក មានសេចក្ដីប្រាថ្នា គ្របសង្កត់ហើយ នេះហៅថា* **និប្បេសិកតា** ។

**តត្ថ កតមា លាភេន លាភំ និជ្ជិគីសនតា**?

*បណ្តាបាបធម៌ទាំងនោះ **លាភេន លាភំ និជ្ជិគីសនតា**តើដូចម្តេច?*

លាភសក្ការសិលោកសន្និស្សិតោ បាបិច្ឆោ ឥច្ឆាបកតោ ឥតោ លទ្ធំ អាមិសំ អមុត្រ ហរតិ អមុត្រ វា លទ្ធំ អាមិសំ ឥធ អាហរតិ ។ យា ឯវរូបា អាមិសេន អាមិសស្ស ឯដ្ឋិ គវេដ្ឋិ បរិយេដ្ឋិ ឯសនា គវេសនា បរិយេសនា អយំ វុច្ចតិ លាភេន លាភំ និជ្ជិគីសនតា ។ *ភិក្ខុអ្នកអាស្រ័យលាភសក្ការៈនិងការសរសើរ មានសេចក្តីប្រាថ្នាលាមក មានសេចក្តីប្រាថ្នាគ្របសង្កត់ហើយ នាំយកនូវអាមិសដែលខ្លួនបានហើយ អំពីផ្ទះឯណេះទៅផ្ទះឯណោះ ឬនាំយកនូវអាមិសដែលខ្លួនបានហើយ អំពីផ្ទះឯណោះមកឲ្យផ្ទះឯណេះ ការប្រាថ្នា ការស្វែងរក ការស្វែងរករឿយៗ ការគន់រក ការរិះរក ការស្វែងរកញឹកញាប់ នូវអាមិសដោយអាមិស មានសភាពយ៉ាងនេះ នេះហៅថា **លាភេន លាភំ និជ្ជិគីសនតា** ។*

**ចត្តារោ ហិ បរិភោគា ថេយ្យបរិភោគោ ឥណបរិភោគោ ទាយជ្ជបរិភោគោ សាមិបរិភោគោ ។** *ការបរិភោគ ៤ យ៉ាងគឺ ៖ បរិភោគដោយលួច ១ បុលបំណុលគេ ១ ទទួលមរតក១ ជាម្ចាស់របស់១ ។*

**ចតុព្វិធា ហិ សុទ្ធិ ទេសនាសុទ្ធិ សំវរសុទ្ធិ បរិយេដ្ឋិសុទ្ធិ, បច្ចវេក្ខណសុទ្ធិតិ។** *ការបរិសុទ្ធិ ៤ យ៉ាងគឺ៖ បរិសុទ្ធិដោយការសម្តែង ១ បរិសុទ្ធិដោយការសង្រួម ១ បរិសុទ្ធិដោយការស្វែងរក១ បរិសុទ្ធិដោយការពិចារណា១ ។*

## ឆ្លើយសំនួរទី ៦, ៧

**៦.ខណ្ឌាទិភាវោ សីលស្ស សំកិលេសោ។** *ភាវដាច់ ធ្លុះ ពពាល ពព្រុះ ជាសេចក្តីសៅហ្មងរបស់សីល ។*

**៧. អខណ្ឌាទិភាវោ វោទានំ ។** *ភាវមិនដាច់ជាដើម ជាសេចក្តីផូរផង់របស់សីល ។*

*** សោ បន ខណ្ឌាទិភាវោ លាភយសាទិហេតុកេន ភេទេន ច សត្តវិធមេថុនសំយោគេន ច សង្គហិតោ** *ក៏ភាវដាច់ជាដើមនោះលោកសង្គ្រោះដោយប្រភេទទីបំផុតព្រោះមានលាភ យស ញាតិ អវយវជីវិតជាហេតុផង ដោយមេថុនសំយោគ ៧ ផង ។*

## ធុតង្គនិទ្ទេស

**ភគវតា ហិ បរិច្ចត្តលោកាមិសានំ. កាយេ ច ជីវិតេ ច អនបេក្ខានំ អនុលោមបដិបទំ អារាធេតុកាមានំ កុលបុត្តានំ តេរសធុតង្គានិ អនុញ្ញាតានិ ។** *ធុតង្គទាំង ១៣ ព្រះមានព្រះភាគទ្រង់អនុញ្ញាតដល់កុលបុត្តទាំងឡាយ អ្នកលះបង់អាមិសក្នុងលោកផង អ្នកមិនអាល័យក្នុងកាយ និងជីវិតផង អ្នកប្រាថ្នាឲ្យព្រះពុទ្ធទាំងឡាយត្រេកអរនឹងបដិបទាដ៏សមគួរផង ។*

# មាតិកាធុតង្គ

១)បំសុកូលិកង្គំ ២)តេចីវរិកង្គំ

៣)បិណ្ឌបាតិកង្គំ ៤)សបទានចារិកង្គំ

៥)ឯកាសនិកង្គំ ៦)បត្តបិណ្ឌិកង្គំ

៧)ខលុបច្ឆាភត្តិកង្គំ ៨)អារញ្ញិកង្គំ

៩)រុក្ខមូលិកង្គំ ១០)អព្ភោកាសិកង្គំ

១១)សោសានិកង្គំ ១២)យថាសន្ថតិកង្គំ

១៣)នេសជ្ជិកង្គំ ។

# លក្ខណៈរៀនធុតង្គទាំង១៣

អត្ថតោ លក្ខណាទីហិ.សមាទានវិធានតោ

បភេទតោ ច.តស្ស តស្សាដិសំសតោ ។

កុសលត្តិកតោ ចេវ.ធុតាទីនំ វិភាគតោ

សមាសព្យាសតោ ចាបិ, វិញ្ញាតព្វោ វិនិច្ឆយោ ។

*អ្នកសិក្សាទាំងឡាយ គប្បីសិក្សាវិនិច្ឆ័យធុតង្គទាំង១៣ ដោយអត្ថ១ ដោយលក្ខណាទិចតុក្ក១ ដោយវិធីសមាទាន១ ដោយប្រភេទ១ ដោយការបែកធ្លាយ១ ដោយអានិសង្ស១ ដោយកុស-លត្តិក:១ ដោយការចែកស័ព្ទ១ ដោយសង្ខេប និងពិស្តា១ ។*

## ១វិនិច្ឆ័យដោយអត្ថ

១) បំសុកូលំ សីលមស្សាតិ បំសុកូលិកោ ។ បំសុកូលិ-កស្ស អង្គំបំសុកូលិកង្គំ ។ *អង្គរបស់ភិក្ខុអ្នកទ្រទ្រង់សំពត់បំសុកូលជាប្រក្រតី ។*

២)សង្ឃាដិឧត្តរាសង្គអន្តរវាសកសង្ខាតំ តិចីវរំ សីលម-ស្សាតិ តេចីវរិកោ ។ តេចិវរិកស្ស អង្គំ តេចីវរិកង្គំ ។ *អង្គរបស់ភិក្ខុអ្នកទ្រទ្រង់ចីវរបីជាប្រក្រតី ។*

៣) បិណ្ឌចាតី ឯវ បិណ្ឌចាតិកោ, បិណ្ឌចាតិកស្ស អង្គំ បិណ្ឌចាតិកង្គំ ។ *អង្គរបស់ភិក្ខុអ្នកត្រាច់ទៅបិណ្ឌបាតជាប្រក្រតី ។*

៤)សបទានចារី ឯវ សបទានចារិកោ ។ តស្ស អង្គំ សបទា-នចារិកង្គំ ។ *អង្គរបស់ភិក្ខុអ្នកត្រាច់ទៅបិណ្ឌបាតតាមលំដាប់ផ្ទះជាប្រក្រតី ។*

៥) ឯកាសនេ ភោជនំ ឯកាសនំ,តំសីលមស្សាតិ ឯកាស-និកោ ។ តស្សអង្គំ ឯកាសនិកង្គំ ។ *អង្គរបស់ភិក្ខុអ្នកឆាន់បិណ្ឌបាតលើកអាសនៈមួយជាប្រក្រតី ។*

៦) បត្តបិណ្ឌកហណោ បត្តបិណ្ឌសញ្ញី កត្វា បត្តបិណ្ឌោ សីលមស្សាតិ បត្តបិណ្ឌិកោ ។ តស្ស អង្គ បត្តបិណ្ឌិកង្គំ ។ *អង្គរបស់ភិក្ខុអ្នកឆាន់បិណ្ឌបាតតែក្នុងបាត ជាប្រក្រតី ។*

៧) បច្ឆាភត្តំ សីលមស្សាតិ បច្ឆាភត្តិកោ ន បច្ឆាភត្តិកោ ខលុបច្ឆាភត្តិកោ ។ តស្ស អង្គំ ខលុបច្ឆាភត្តិកង្គំ ។ *អង្គរបស់ភិក្ខុអ្នកហាមភត្តហើយមិនឆាន់អតិរិត្តភោជនទៀតជាប្រក្រតី។*

៨)អរញ្ញេ និវាសោ សីលមស្សាតិ អារញ្ញិកោ ។ តស្ស អង្គំ អារញ្ញិកង្គំ ។ *អង្គរបស់ភិក្ខុអ្នកនៅក្នុងព្រៃជាប្រក្រតី ។*

៩) រុក្ខមូលេ និវាសេ រុក្ខមូលំ តំ សីលមស្សាតិ រុក្ខមូលិ-កោ រុក្ខមូលិកស្ស អង្គំ រុក្ខមូលិកង្គំ ។ *អង្គរបស់ភិក្ខុអ្នកនៅទៀបគល់ឈើជាប្រក្រតី ។*

១០) អព្ភោកាសេ និវាសោ អព្ភោកាសោ តំសីលមស្សាតិ អព្ភោកាសិកោ អព្ភោកាសិកស្ស អង្គំ អព្ភោកាសិកង្គំ ។ *អង្គរបស់ភិក្ខុអ្នកនៅក្នុងទីវាលជាប្រក្រតី ។*

១១) សោសានេ និវាសោ សោសានោ, តំសីលមស្សាតិ សោសានិកោ, សោសានិកស្ស អង្គំ សោសានិកង្គំ ។ *អង្គរបស់ភិក្ខុអ្នកនៅក្នុងទីស្មសានជាប្រក្រតី ។*

១២) សយនំ បដិក្ខិត្វា និសជ្ជាយ វិហារិតុំ សីលមស្សាតិ យថាសន្ថតិកោ,តស្ស អង្គំ យថាសន្ថតិកង្គំ ។ *អង្គរបស់ភិក្ខុអ្នកមានកិរិយានៅក្នុងទីសេនាសនៈតាមការចាត់ជាប្រក្រតី ។*

១៣)សយនំ បដិក្ខិត្វា និសជ្ជាយ វិហារិតុំ សីលមស្សាតិ នេសជ្ជិកោ, តស្ស អង្គំ នេសជ្ជិកង្គំ ។ *អង្គរបស់ភិក្ខុអ្នកមិន(ប្រព្រឹត្ត) ឥរិយាបទដេកជាប្រក្រតី ។*

## ២ .វិនិច្ឆ័យដោយលក្ខណាទិចតុក្ក

ក) សមាទានចេតនាលក្ខណានិ *ធុតង្គមានការសមាទានចេតនា ជាលក្ខណៈ ។*

ខ) **លោលុប្បវិទ្ធំសនរសាធិ** *ធុតង្គមានការកំចាត់សេចក្តីល្មោភ ជាកិច្ច ។*

គ) **និល្លោលុប្បការបច្ចុប្បដ្ឋានាធិ** *ធុតង្គមិនមានសេចក្តីល្មោភ ជាអាការប្រាកដ ។*

ឃ) **អប្បិច្ឆតាធិអរិយធម្មបទដ្ឋានាធិ** *ធុតង្គមានសេចក្តីប្រាថ្នាតិចជាដើម និងអរិយធម៌ជាហេតុជិត ។*

## ៣.ចនិច្ឆ័យដោយវធីសមាទាន

១. **គហាបតិធានចីវរំ បដិក្ខិចាមិ** *ខ្ញុំព្រះករុណា សូមហាមនូវគហបតីចីវរ ។* **បំសុកូលិកង្គំ សមាធិយាមិ***ខ្ញុំព្រះករុណា សូមសមាទាននូវអង្គរបស់ភិក្ខុអ្នកទ្រទ្រង់សំពត់បំសុកូលជាប្រក្រតី ។*

២. **ចតុត្ថកាចីវរំ បដិក្ខិបាមិ** *ខ្ញុំព្រះករុណា សូមហាមនូវចីវរទី៤* ។ **តេចីវរិកង្គំ សមាទិយាមិ** *ខ្ញុំព្រះករុណា សូមសមាទាននូវអង្គរបស់ភិក្ខុអ្នកទ្រទ្រង់ចីវរ៣ជាប្រក្រតី* ។

៣. **អតិរេកលាភំ បដិក្ខិបាមិ** *ខ្ញុំព្រះករុណា សូមមិនទទួលភត្ត ១៤* ។ **បិណ្ឌបាតិកង្គំ សមាទិយាមិ** *ខ្ញុំព្រះករុណា សូមសមាទាននូវអង្គរបស់ភិក្ខុអ្នកត្រាច់ទៅបិណ្ឌបាតជាប្រក្រតី* ។

៤. **លោលុប្បចារំ បដិក្ខិបាមិ** *ខ្ញុំព្រះករុណា សូមហាមនូវការកន្លងឧបចារៈ* ។ **សបទានចារិកង្គំ សមាទិយាមិ***ខ្ញុំព្រះករុណា សូមសមាទាននូវអង្គរបស់ភិក្ខុ អ្នកត្រាច់ទៅបិណ្ឌបាតតាមលំដាប់ផ្ទះ ជាប្រក្រតី* ។

៥. **នានាសនភោជនំ បដិក្ខិបាមិ** *ខ្ញុំព្រះករុណា សូមហាមការឆាន់លើអាសនៈផ្សេងៗ* ។ **ឯកាសនិកង្គំ សមាទិយាមិ** *ខ្ញុំព្រះករុណា សូមសមាទាននូវអង្គរបស់ភិក្ខុអ្នកឆាន់បិណ្ឌបាតលើអាសនៈមួយជាប្រក្រតី* ។

**៦. ទុតិយកភាជនំ បដិក្ខិចាមិ** ខ្ញុំព្រះករុណា សូមហាមនូវភាជនៈទី ២ ។ **បត្តបិណ្ឌិកង្គំ សមាទិយាមិ** ខ្ញុំព្រះករុណា សូមសមាទាននូវអង្គរបស់ភិក្ខុ អ្នកឆាន់បិណ្ឌបាតតែក្នុងបាត្រជាប្រក្រតី ។

**៧. អតិរិត្តភោជនំ បដិក្ខិចាមិ** ខ្ញុំព្រះករុណា សូមហាមនូវការឆាន់អតិរិត្តភោជន ។ **ខលុបច្ឆាភត្តិកង្គំ សមាទិយាមិ** ខ្ញុំព្រះករុណា សូមសមាទាននូវអង្គរបស់ភិក្ខុអ្នកហាមភត្តហើយ មិនឆាន់អតិរិត្តភោជនទៀតជាប្រក្រតី ។

**៨) គាមន្តសេណាសនំ បដិក្ខិចាមិ** ខ្ញុំព្រះករុណាសូមហាមនូវសេនាសនៈខាងក្នុងស្រុក ។ **អារញ្ញិកង្គំ សមាទិយាមិ** ខ្ញុំព្រះ-ករុណា សូមសមាទាននូវអង្គរបស់ភិក្ខុអ្នកនៅក្នុងព្រៃជាប្រក្រតី ។

៩) **ឆន្នំ បដិក្ខិបាមិ** ខ្ញុំព្រះករុណាសូមហាមនូវទីប្រក ។ **រុក្ខមូលិកង្គំ សមាទិយាមិ** ខ្ញុំព្រះករុណា សូមសមាទាននូវអង្គរបស់ភិក្ខុអ្នកនៅទៀបគល់ឈើជាប្រក្រតី ។

១០) **ឆន្នញ្ច រុក្ខមូលញ្ច បដិក្ខិបាមិ** ខ្ញុំព្រះករុណា សូមហាមនូវទីប្រកផង គល់ឈើផង ។ **អព្ភោកាសិកង្គំ សមាទិយាមិ** ខ្ញុំព្រះករុណា សូមសមាទាននូវអង្គរបស់ភិក្ខុអ្នកនូវក្នុងទីវាលជាប្រក្រតី។

១១) **ន សុសានំ បដិក្ខិបាមិ** ខ្ញុំព្រះករុណា សូមហាមនូវទីមិនមែនជាទីស្មសាន ។ **សោសានិកង្គំ សមាទិយាមិ** ខ្ញុំព្រះ-ករុណា សូមសមាទាននូវអង្គរបស់ភិក្ខុអ្នកមានកិរិយានូវ ក្នុងទីស្មសានជាប្រក្រតី ។

១២) **សេនាសនលោលុប្បំ បដិក្ខិបាមិ** ខ្ញុំព្រះករុណា សូមហាមនូវសេនាសនៈតាមសេចក្តីត្រូវការ ។ **យថាសន្ថតិកង្គំ**

**សមាទិយាមិ** *ខ្ញុំព្រះករុណា សូមសមាទាននូវអង្គរបស់ភិក្ខុអ្នកមានកិរិយានៅក្នុងទីសេនាសនៈតាមការចាត់ជាប្រក្រតី ។*

**១៣) សេយ្យំ បដិក្ខិបាមិ** *ខ្ញុំព្រះករុណា សូមហាមនូវឥរិយាបថដេក ។* **នេសជ្ជិកង្គំ សមាទិយាមិ** *ខ្ញុំព្រះករុណា សូមសមាទាននូវអង្គរបស់ភិក្ខុអ្នកមិនដេកជាប្រក្រតី ។*

**ឥមេសុ ទ្វីសុ វចនេសុ អញ្ញតរេន សមាទិន្នំ ហោតិ ។** *បណ្ដាពាក្យសមាទាន ទាំងពីរយ៉ាងនេះ សមាទានដោយពាក្យណាមួយក៏បាន ។*

## ៤ ធុតង្គវិនិច្ឆ័យដោយប្រភេទ

*ធុតង្គទាំងអស់ដោយប្រភេទមាន ៣ ប្រភេទគឺ៖*

**ឧក្កដ្ឋោ** *ឧក្រិត១* **មជ្ឈិមោ** *កណ្ដាល១* **មុទុ** *ទន់ខ្សោយ១ ។*

## ៥ ធុតង្គវិនិច្ឆ័យដោយការបែកធ្លាយ

**១ តេសុ យស្ស កស្សចិ អត្ថតោ រុចិយា គិហិនិន្នកាំ សាទិត-ក្ខណោ ធុតង្គំ ភិជ្ជតិ ។** *បំសុកូលិកង្គធុតង្គទាំង ៣ ប្រភេទនោះ រមែងបែកធ្លាយក្នុងខណៈត្រេកអរទទួលនូវចីវរដែលគ្រហស្ថ (បុគ្គលណាមួយ ) ប្រគេន ។*

**២ ឥមេសំ បន តិណ្ណម្បិ ចតុត្ថកាចីវរំ សាទិតក្ខណោយេវ ធុតង្គំ ភិជ្ជតិ ។** *ចំណែកតេចីវរិកទាំង ៣ប្រភេទ រមែងបែកធ្លាយក្នុងខណៈត្រេកអរទទួលប្រើនូវចីវរទី ៤ ។*

**៣ ឥមេសំ បន តិណ្ណម្បិ សង្ឃភត្តាទិអតិរេកលាភំ សាទិត-ក្ខណោវ ធុតង្គំ ភិជ្ជតិ ។** *ចំណែកបិណ្ឌបាតិកង្គទាំង ៣ ប្រភេទ រមែងបែកធ្លាយ ក្នុងខណៈត្រេកអរទទួលអតិរេកលាភមាន សង្ឃភត្តជាដើម ។*

**៤ ឥមេសំ បន តិណ្ណម្បិ លោលុប្បចារេ ឧប្បន្នមត្តេ ធុតង្គំ ភិជ្ជតិ ។** *ចំណែកសបទានចារិកង្គទាំង ៣ ប្រភេទ រមែងបែកធ្លាយក្នុងខណៈត្រឹមតែកើតសេចក្តីល្មោភក្នុងឧបចារផ្ទះ ។*

**៥ ឥមេសំ បន តិណ្ណម្បិ នានាសនភោជនំ កុត្តក្ខណេ ធុតង្គំ ភិជ្ជតិ ។** *ចំណែកឯកាសនិកង្គទាំង ៣ ប្រភេទ រមែងបែកធ្លាយក្នុងខណៈឆាន់ភោជនលើអាសនៈទី២ ។*

**៦ ឥមេសំ បន តិណ្ណម្បិ ទុតិយកភាជនំ សាទិតក្ខណេ ធុតង្គំ ភិជ្ជតិ ។** *ចំណែកបត្តបិណ្ឌិកង្គទាំង ៣ ប្រភេទ រមែងបែកធ្លាយក្នុងខណៈត្រេកអរប្រើភាជន៍ទី២ ។*

**៧ ឥមេសំ បន តិណ្ណម្បិ បវារិតានំ កប្បិយំ ការាបេត្វា កុត្តក្ខណេ ធុតង្គំ ភិជ្ជតិ ។** *ចំណែកខលុបច្ឆាភត្តិកង្គទាំង ៣ ប្រភេទ រមែងបែកធ្លាយក្នុងខណៈភិក្ខុហាមនោះប្រើគេឲធ្វើកប្បិយហើយឆាន់ ។*

**៨ តាមគ្គសេជាសនេ អរុណំ ឧដ្ឋបេត្តិ ធុតង្គំ ភិជ្ជតិ ។** *ចំណែកអារញ្ញិកង្គទាំង ៣ប្រភេទ រមែងបែកធ្លាយក្នុងខណៈភិក្ខុនោះនៅក្នុងស្រុករហូតអរុណរះឡើង ។*

**៩ ឥមេសំ បន តិណ្ណម្បិ ឆន្នេ វាសំ កប្បិតក្ខណេ ធុតង្គំ ភិជ្ជតិ ។ ជានិត្វា ឆន្នេ អរុណំ ឧដ្ឋាបិតមត្តេតិ អង្គុត្តរភាណកា** *។ចំណែករុក្ខមូលិកង្គទាំង ៣ ប្រភេទ រមែងបែកធ្លាយក្នុងខណៈសម្រេចនៅក្នុងទីប្រកនិងត្រឹមតែដឹងហើយ នៅក្នុងទីប្រក់រហូតអរុណរះឡើង ។*

**១០ ឥមេសំ បន តិណ្ណម្បិ វាសត្ថាយ ឆន្នំ វា រុក្ខមូលំ វា បវិដ្ឋក្ខណេ ធុតង្គំ ភិជ្ជតិ ។ ជានិត្វា តត្ថ អរុណំ ឧដ្ឋាបិតមត្តេតិ អង្គុត្តរភាណកា** ។ *ចំណែកអព្ភោកាសិកង្គទាំង ៣ប្រភេទ រមែងបែកធ្លាយ ក្នុងខណៈចូលទៅកាន់ទីប្រក់ និងទៀបគល់ឈើដើម្បីនៅ ។ ឬដឹងហើយទៅកាន់ទីប្រក់ ទីទៀបគល់ឈើនៅរហូតអរុណរះឡើង ។*

**១១ ឥមេសំ បន តិណ្ណម្បិ ន សុសានម្ហិ វាសំ កប្បេនេន ធុតង្គំ ភិជ្ជតិ ។ សុសានំ អគតទិវសេតិ អត្ថុតរភាណកា ។** *ចំណែកសោសានិកង្គទាំង៣ ប្រភេទ រមែងបែកធ្លាយក្នុងខណៈសម្រេចទីនៅមិនមែនជាទីស្មសាន ។ ក្នុងថ្ងៃមិនទៅទីស្មសាន ។*

**១២ ឥមេសំ បន តិណ្ណម្បិ សេនាសនលោលុប្បេ ឧប្បន្នមត្តេ ធុតង្គំ ភិជ្ជតិ ។** *ចំណែកយថាសន្ថតិកង្គទាំ ៣ ប្រភេទ រមែងបែកធ្លាយក្នុងខណៈសេចក្តីល្មោភក្នុងសេនាសនកើតឡើង ។*

**១៣ ឥមេសំ បន តិណ្ណម្បិ សេយ្យំ កប្បិតមត្តេ ធុតង្គំ ភិជ្ជតិ។** *ចំណែកនេសជ្ជិកង្គទាំង ៣ ប្រភេទ រមែងបែកធ្លាយក្នុងខណៈត្រឹមតែសម្រេចឥរិយាបថដេក ។*

## ៦ ចរិតច្ឆ័យដោយអានិសង្ស

## ចានធុវគុណ ៩ យ៉ាងជាដើម

១.អប្បិច្ឆតា *ប្រាថ្នាតិច*

២.សន្តុដ្ឋិតា *សន្តោស*

៣.សល្លេខតា *ការដុសខាត់កិលេស*

៤.បវិវេកា *សេចក្ដីស្ងាប់ស្ងាត់*

៥.អបចយ *ការមិនសន្សំ*

៦.វីរិយារម្ភ *ព្យាយាម*

៧.សុភរតា *គេចិញ្ចឹមងាយ*

៨.អប្បកិច្ចតា *មានកិច្ចធុរៈតិច*

៩.សល្លហុកវុត្តិ *ប្រព្រឹត្តស្រាយ*

**៧ វិនិច្ឆ័យដោយកុសលត្តិក:**

តត្ថ កុសលត្តិកតោតិ សព្វានេវ ហិ ធុតង្គានិ. សេក្ខបុថុជ្ជនខីណាសវានំ វសេន សិយា កុសលានិ សុយា.អព្យាកតានិ នត្ថិ. ធុតង្គំ អកុសលំ ។

*បណ្តាពាក្យទាំងនោះ ដោយពាក្យថា* ***កុសលត្តិកដូច្នេះ*** *មានសេចក្តីថា ពិតមែន ធុតង្គទាំងអស់ជាកុសលគប្បីមាន ដោយអំណាចព្រះសេក្ខ:និងបុថុជ្ជន, ជាអព្យាគតគប្បីមានដោយអំណាចព្រះខីណាស្រព, ធុតង្គដែលជាអកុសលមិនមានទេ ។*

**៨ ដោយការចែកមានធុតជាដើម**

ធុតោ វេទិតព្វោ ។ ធុតវាទោ វេទិតព្វោ ។ ធុតធម្មា វេទិតព្វា។ ធុតង្គានិ វេទិតព្វានិ ។ *គប្បីជ្រាបដោយធុត. ធុតវាទ. ធុតធម៌. ធុតង្គ ។* កស្ស ធុតង្គសេវនា សប្បាតិ រាគចរិតស្ស ចេវ មោហចរិតស្ស ច ។ *តើធុតង្គទាំង ១៣ ជាសប្បាយដល់បុគ្គល*

*ណាខ្លះ ? ធុតង្គទាំ ១៣ ជាសប្បាយដល់បុគ្គលរាគៈចរិត និង មោហចរិត ។*

## ៩ ដោយសង្ខេប និងពិស្តារ

**ឥមានិ បន ធុតង្គានិ  សមាសតោ តីណិ សីសង្គានិ. បញ្ច អសម្ភិន្នង្គានីតិ អដ្ឋេវ ហោន្តិ ។** *ធុតង្គទាំងអស់នេះ  ដោយសង្ខេបមាន៨ គឺ ធុតង្គជាប្រធាន ៣ ធុតង្គមិនលាយគ្នា ៥ ។*

**ព្យាសតោ បន ភិក្ខូនំ តេរស ភិក្ខូនីនំ អដ្ឋ សាមណេរានំ ទ្វាទស សិក្ខមានសាមណេរីនំ សត្ត ឧចាសកឧចាសកា-នំ  ទ្វេតិ ទ្វាចត្តាឡីស ហោន្តិ ។** *ដោយពិស្តារមាន ៤២ គឺ ធុតង្គទាំង ១៣ គួរដល់ភិក្ខុ.ធុតង្គ ៨ គួរដល់ភិក្ខុនី. ធុតង្គ ១២ គួរដល់សាមណេរ. ធុតង្គ ៧ គួរដល់សិក្ខមានា សាមណេរី. ធុតង្គ២ គួរដល់ដល់ឧបាសកឧបាសិកា ។*

**ចប់ វិសុទ្ធិមគ្គ(សម្រាប់សូត្រ) ៗ៕**

សូមពន្យល់តារាងចែកធុតង្គដោយពិស្តារ និងសង្ខេបខាងក្រោមនេះ ឲ្យល្អមដឹងបានស្រួល

<table>
<tr><th colspan="5">ចែកធុតង្គ ១៣ ដោយពិស្តារមាន ៤២</th><th>ល.រ,មាតិកា</th><th>សង្ខេប</th><th>បដិសមយុត្ត</th></tr>
<tr><td rowspan="13">ធុតង្គទាំង ១៣ គួរដល់ភិក្ខុទាំងអស់</td><td rowspan="6">ភិក្ខុនី</td><td colspan="2">សាមណេរ,...រី សិក្ខមានា</td><td rowspan="4">ដក</td><td>១ បំសុកូលិកង្គ</td><td rowspan="2">មិន</td><td rowspan="2">ចីវរ</td></tr>
<tr><td colspan="2">ដក</td><td>២ តេចីវរិកង្គ</td></tr>
<tr><td rowspan="11">សាមណេរ</td><td rowspan="4">សិក្ខមានា សាមណេរី</td><td>៣ បិណ្ឌបាតិកង្គ</td><td>ចូល</td><td rowspan="5">បណ្ឌិបាត</td></tr>
<tr><td>៤ សបទានចារិកង្គ ↓</td><td rowspan="2">ប្រធាន</td></tr>
<tr><td>ឧ.ស</td><td>៥ ឯកាសនិកង្គ ↑</td></tr>
<tr><td>ឧ.សិ</td><td>៦ បត្តបិណ្ឌិកង្គ</td><td rowspan="2">ចូល</td></tr>
<tr><td rowspan="2">២ នេះហាម</td><td rowspan="5">ដក</td><td rowspan="7">ដក</td><td>៧ ខលុបច្ឆាភត្តិកង្គ</td></tr>
<tr><td>៨ អារញ្ញិកង្គ</td><td>មិន</td><td rowspan="5">សេនាសនៈ</td></tr>
<tr><td rowspan="3">៣នេះរក្សាបានដោយកម្រ</td><td>៩ រុក្ខមូលិកង្គ</td><td>ចូល</td></tr>
<tr><td>១០ អព្ភោកាសិកង្គ ↓↑</td><td>ប្រធាន</td></tr>
<tr><td>១២ យថាសន្ថតិកង្គ</td><td>ចូល</td></tr>
<tr><td rowspan="2">ភិក្ខុនី</td><td rowspan="2">សាមណេរ<br>សិក្ខមានា</td><td>១១ សោសានិកង្គ</td><td>មិន</td></tr>
<tr><td>១៣ នេសជ្ជិកង្គ</td><td>មិន</td><td>វិរិយ</td></tr>
<tr><td>១៣</td><td>+៨</td><td>+១២</td><td>+៧</td><td>+២</td><td>=៤២</td><td>៨</td><td>៤</td></tr>
<tr><td colspan="8">ទាំង១៣ចែកជា ២ គឺ គួរសេព ១ មិនគួរសេព១ ។ ចែកជាធុត, ធុតវាទ, ធុតធម្ម, ធុតង្គ ។</td></tr>
</table>

**ស្រួលណាស់ត្រង់ថា លំបាកអស្ចារ្យ នៅត្រង់ប្រព្រឹត្ត ។**

**ធម្មទានដោយ**

- ព្រះត្រៃបិដកវេជ្ជីវជ័ តុន ព្រមទាំងពុទ្ធវិស័ធ

សព្វទានំ ធម្មទានំ ជិនាតិ ធម្មទានឈ្នះអស់ទានទាំងពួង ។



សាមណេរ មនោរេជ យ៉ុង តាក

សីលេខតិក្លាយ នមាសញ្ញា ចិត្តបញ្ញាញូ

តាវយំ អាតាបី និមពោ ភិក្ខុ សោ គត់ វៃនមោ ជជំ ។

[illegible]

[illegible]

[illegible]

[illegible] ។